# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

### ប្រចាំខែ ធ្នូ និងប្រចាំឆ្នាំ ២០១៤/December, 2014

| មាតិកា | ទំព័រ |
|---|---|
| ១. សន្ទស្សន៍ថ្លៃទំនិញ/Consumer price index | ២ |
| ២. វិស័យហិរញ្ញវត្ថុ /Finance | ២ |
| ៣. វិស័យពាណិជ្ជកម្ម/Trades | ២ |
| ៤. ការអនុវត្តថវិកា/Budget execution | ៣ |
| ៥. វិស័យវិនិយោគឯកជន/Private investment | ៤ |
| ៦. វិស័យទេសចរណ៍/Tourism | ៤ |
| ៧. វិស័យសំណង់/Construction | ៥ |
| ៨. ថ្លៃប្រេងឆៅ (Crude oil price average: Brent; Dubai; WTI) | ៥ |
| ៩. ថ្លៃអង្ករ (Rice price: 5 ភាគរយ; 25 ភាគរយ; 100 ភាគរយ broken) | ៥ |
| ១០. ថ្លៃកៅស៊ូ (Rubber price: SGP/MYS; TSR20) | ៦ |
| ១១. ឧបសម្ព័ន្ធ | ៧ |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៥

**ប្រធាននាយកដ្ឋានស្ថិតិ**

# សន្ទេបនិន្នាការសេដ្ឋកិច្ចសង្គម

**១. សន្ទស្សន៍ថ្លៃទំនិញ (Consumer price index)÷** តាមប្រភពពីវិទ្យាស្ថានជាតិស្ថិតិបង្ហាញថា នៅខែ ធ្នូ ឆ្នាំ ២០១៤ សន្ទស្សន៍ថ្លៃទំនិញ ប្រើប្រាស់បានបន្តថយចុះចំនួន ០,៧ ភាគរយ ធៀបនឹងខែកន្លងទៅ ។ ជារួម សំរាប់ឆ្នាំ ២០១៤ អតិផរណាមធ្យម ប្រចាំឆ្នាំ (year average) មានកំរិត ៣,៩ ភាគរយ និងអតិផរណាប្រចាំឆ្នាំ (year on year) មានអត្រា ១,១ ភាគរយ ។ ក្នុងចំណោមសន្ទស្សន៍ថ្លៃទាំង ១២ ក្រុម មានតែសន្ទស្សន៍គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ និងការថែទាំទេ ដែលកើន ឡើងខ្ពស់ដល់ទៅ ៦,៣ ភាគរយ ក្រៅពីនោះ គឺស្ថិតនៅក្រោម ៥ ភាគរយ ឬ ទាបជាងឆ្នាំកន្លងទៅ ដូចជាសន្ទស្សន៍ថ្លៃការដឹកជញ្ជូន សន្ទស្សន៍ថ្លៃផ្ទះ សំបែង ទឹក អគ្គិសនី ឧស្ម័ន និង ឥន្ធនៈដទៃទៀត សន្ទស្សន៍ថ្លៃ គមនាគមន៍ និង សន្ទស្សន៍ថ្លៃទំនិញ និង សេវាកម្មផ្សេងៗ ។ សន្ទស្សន៍ថ្លៃភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ខ្ពស់បង្គួរដោយសារមាន ការកែសម្រួល អត្រាអាករពិសេសលើបារីនិងស្រា ។

តាមការសង្កេត ទោះបីអតិផរណានៅឆ្នាំ ២០១៤ មានកំរិតទាបក៏ដោយ ក៏មានទំនិញប្រើប្រាស់មួយចំនួន មានការប្រែប្រួលគួរឲ្យកត់សម្គាល់ដែរ ដូចជាសាច់ជ្រូកនៅលើទីផ្សារបានកើនឡើងដល់ទៅ ៨,១ ភាគរយ ទន្ទឹមនឹងថ្លៃជ្រូករស់នៅតាមកសិដ្ឋាននានាបានធ្លាក់ចុះប្រមាណជា ២០ ភាគរយ បន្លែនិងផ្លែឈើនាំចូលមួយចំនួនបានកើនឡើង ជាង ៦ ភាគរយ គ្រឿងសម្ភារៈសាងសង់បានកើនឡើង ៧ ភាគរយ និងថ្លៃផ្តល់សេវាផ្សេងៗបានកើនឡើងជាង ៧ ភាគរយ ។ ទោះជាយ៉ាងនេះក្តី ថ្លៃប្រេង ឧស្ម័ន និងឥន្ធនៈ រាវបានថយចុះប្រមាណ ១៧ ភាគរយ ដោយសារតម្លៃ និងតម្រូវការប្រេង នៅលើទីផ្សារអន្តរជាតិធ្លាក់ចុះ ។ ការថយចុះថ្លៃប្រេងឥន្ធនៈនេះ ក៏បានធ្វើឲ្យថ្លៃទំនិញនិងសេវាពាក់ព័ន្ធមួយចំនួនធ្លាក់ចុះ ដែរ ដូចជាថ្លៃដឹក ជញ្ជូនបានថយចុះ ៦,៩ ភាគរយ ជាដើម ។

**២. វិស័យហិរញ្ញវត្ថុ/រូបិយវត្ថុ (Finance/Monetary)** ÷ក្នុងរយៈពេល៤ឆ្នាំចុងក្រោយនេះ រូបិយវត្ថុទូទៅ (M2) មានកំណើនជាមធ្យមចំនួន ២១,៧ ភាគរយ/ឆ្នាំ ក្នុងនោះ រូបិយវត្ថុ (M1) បានកើនឡើងចំនួន ១៨,៧ ភាគរយ និងរូបិយវត្ថុផ្សេងៗ បានកើនឡើង ២២,៣ ភាគរយ ។ សម្រាប់ប្រាក់បញ្ញើចរន្ត (បញ្ញើជាប្រាក់រៀល) ទោះបីមានបរិមាណតិច ប៉ុន្តែកំណើនជាមធ្យម ប្រមាណជា ៥៥,៧ ភាគរយ ដោយសារកំណើនការប្រើប្រាស់ប្រព័ន្ធធនាគារលើប្រតិបត្តិការប្រាក់បៀវត្សមន្ត្រីរាជការ ការបង់ពន្ធដារ បង់វិក័យបត្រទឹក ភ្លើង និងទីផ្សារមូលបត្រជាដើម ។

នៅឆ្នាំ ២០១៤ នេះ ប្រាក់រៀលចរាចរនៅលើទីផ្សារបានកើនឡើងចំនួន ២៧ ភាគរយ ធៀបទៅនឹងឆ្នាំមុន ហើយអត្រាសាច់ប្រាក់រៀលធៀបរូបិយវត្ថុទូទៅ (M2) មានចំនួន ១៧,៤ ភាគរយ រីឯអត្រាស្រាច់ប្រាក់ ប្រើប្រាស់ជារូបិយប័ណ្ណបរទេសធៀបរូបិយវត្ថុទូទៅ (M2) មានចំនួន ៨២,៦ ភាគរយ ដែលនេះបញ្ជាក់ថាដុល្លារូបនីយកម្មនៅកម្ពុជានៅតែមានកំរិតខ្ពស់ ។

**៣. វិស័យពាណិជ្ជកម្ម (Trades)÷** នៅឆ្នាំ ២០១៤ ការនាំចូលមានទំហំជាទឹកប្រាក់ប្រមាណ ១០.២៩៦,០ លានដុល្លារ បានកើនឡើង ១៧,៦ ភាគរយ ធៀបនឹងឆ្នាំ ២០១៣ ។ ការនាំចូលមកកាន់កម្ពុជាក្នុងឆ្នាំ ២០១៤ មានកំណើន

១៧,៦ ភាគរយ ទាបជាងឆ្នាំមុនបន្តិច ក្នុងនោះការនាំចូលផលិតផលវាយនភណ្ឌ ដែលជាវត្ថុធាតុដើមសម្រាប់បំរើឱ្យវិស័យកាត់ដេរមានការកើនឡើងត្រឹមតែ ៧,៩ ភាគរយ និង ការនាំចូលសំភារៈ សំណង់កើន ឡើង ៣៤ ភាគរយ ។

នៅឆ្នាំ ២០១៤ ការនាំចេញសរុបសម្រេចបាន ៨.០៨៩,៧ លានដុល្លារ កើនឡើងប្រមាណ ១៦,១ ភាគរយ ធៀបទៅនឹងឆ្នាំ២០១៣ ក្នុងនោះការនាំចេញផលិតផលវាយណភណ្ឌបានកើនឡើង ១០,៧ ភាគរយ ការនាំចេញអង្ករ (គិតជាបរិមាណ)កើនឡើង ២,៥ ភាគរយ និងការនាំចេញកៅស៊ូ (គិតជាបរិមាណ) កើនឡើង ២៨,៦ ភាគរយ ។

**៤. ថវិកា (Budget execution)÷** នៅក្នុងឆ្នាំ ២០១៤ ចំណូលក្នុងស្រុកអនុវត្តបានចំនួន ១០.៦០៣,២១ ពាន់លានរៀល (ប្រមាណ ១៥,៦៥ ភាគរយ នៃ ផសស[1]) គឺកើនឡើង ២០,៨៥ ភាគរយ បើធៀបទៅនឹងរយៈ ពេលដូចគ្នានៅឆ្នាំ ២០១៣ ក្នុងនោះចំណូលពីអគ្គនាយកដ្ឋានពន្ធដារកើនឡើង ១៨,១១ ភាគរយ និង អគ្គនាយកដ្ឋានគយ និងរដ្ឋាករកើនឡើង ៣១,៣៦ ភាគរយ ។ ចំណូល ចរន្តអនុវត្តបាន ១០.៤១៩,២២ ពាន់លានរៀល គឺបានកើន ឡើង ១៩,៦៨ ភាគរយ បើធៀបនឹងឆ្នាំ ២០១៣ ក្នុងនោះ ចំណូលសារពើពន្ធបានកើនឡើង ២៤,៧៩ ភាគរយ ។ ចំណូលពន្ធផ្ទាល់អនុវត្តបាន ១.៩៦៣,១៣ ពាន់លានរៀល គឺបានកើនឡើង ២៥,៧២ ភាគរយ បើធៀបនឹងឆ្នាំ ២០១៣ ក្នុងនោះការប្រមូលចំណូលពីពន្ធលើប្រាក់បៀវត្សកើនឡើង ២៩,៤៨ ភាគរយ និងចំណូលពីពន្ធលើប្រាក់ចំណេញបានកើនឡើង ២៣,៨២ ភាគរយ ។ ចំណូលពន្ធប្រយោលអនុវត្តបាន ៥.៣០៩,១៣ ពាន់លានរៀល គឺបានឡើង ២៥,៣៨ ភាគរយ ធៀបនឹងឆ្នាំ ២០១៣ ក្នុងនោះចំណូលពីពន្ធលើតម្លៃបន្ថែម (VAT) កើនឡើង ២១,៨៨ ភាគរយ និង ចំណូលពីពន្ធលើអាករពិសេស (Excise Tax) កើនឡើង ៣១,៦២ ភាគរយ ។ ការកើន ឡើងនៃចំណូលពន្ធក្នុងស្រុកនេះ គឺដោយសារការខិតខំប្រឹងប្រែងពី អគ្គនាយកដ្ឋានពន្ធដារ ១)ការពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេសលើទំនិញក្នុងស្រុក ២)ការពង្រីកមូលដ្ឋានជាប់ពន្ធ ក្នុងរបបស្វ័យប្រកាស ៣) ទប់ស្កាត់អំពើ ជៀសវាងពន្ធ (Tax Avoidance) គេចវេះពន្ធ (Tax Evasion) ៤) ការធ្វើទំនើបកម្មប្រព័ន្ធព័តិមានវិទ្យា ៥)ការពង្រឹងការធ្វើសវនកម្ម និង ៦)ការអនុវត្តប្រមូលបំណុលដោយពង្រឹងការបង់ សងតាមដំណាក់កាល (down payment) ។ ចំណែកឯ ចំណូលពន្ធពីពាណិជ្ជកម្មក្រៅប្រទេសអនុវត្តបាន ១.៨២៣,៦៦ ពាន់លានរៀលគឺបាន កើនឡើង ២២,១៥ ភាគរយ បើធៀបនឹង ឆ្នាំ ២០១៣ ក្នុងនោះ ចំណូលពីពន្ធពីការនាំចូលបានកើនឡើង ២៥,៧៥ ភាគរយ និង ចំណូលពីពន្ធលើការនាំចេញកើនឡើង ៩,០៩ ភាគរយ ។ ការកើនឡើងនៃចំណូល ពាណិជ្ជកម្មក្រៅ ប្រទេសគឺបានដោយសារការចាត់វិធានការពី អគ្គនាយកដ្ឋានគយ និងរដ្ឋាករអនុវត្តដូចជា ១)ពង្រឹង ការពិនិត្យទំនិញ នាំចេញ-នាំចូល ២)ការបង្ក្រាបអំពើរត់គេចពន្ធ និងវិធានការផ្សេងៗទៀត ។ ចំណូលមិនមែនសារពើពន្ធ អនុវត្តបាន ១.៣២៣,២៩ ពាន់លានរៀលគឺ បានថយចុះ ៦,៥៩ ភាគរយ ធៀបនឹងឆ្នាំ ២០១៣ ដោយសារតែការធ្លាក់ ចុះ ចំណូលមួយចំនួនដូចជា÷ ចំណូលពីទេសាទ ៧,១៣ ភាគរយ ចំណូលពីព្រៃឈើ ១៧,៣០ ភាគរយ ចំណូលពី ទេសចរណ៍ ៥,៥៨ ភាគរយ ចំណូលពីប្រៃសណីយ៍ និង ទូរគមនាគមន៍ ៤,៦១ ភាគរយ និង ចំណូលពីសារពើពន្ធផ្សេងទៀត ១៩,៤៣ ភាគរយ ។

ក្នុងឆ្នាំ ២០១៤នេះ ចំណាយសរុបអនុវត្តបានចំនួន ១៣.៣០៦,៥២ ពាន់លានរៀល (ប្រមាណ ១៩,៦៣ ភាគរយ នៃ ផសស) គឺខ្ពស់ជាង ៣,១៧ ភាគរយ ធៀបទៅនឹងឆ្នាំ ២០១៣ ក្នុងនោះ ចំណាយចរន្ត កើនឡើង ៥,៩៥ ភាគរយ ។

[1] ចំណូលក្នុងស្រុកសរុបធៀបនឹងផលិតផលក្នុងស្រុកសរុប (ផសស) ឆ្នាំ ២០១៤ ប្រមាណ ៦៧ ៣៤៣ ពាន់ លានរៀល

ជារួម ចំណាយលើប្រាក់បៀវត្សអនុវត្តបាន ៣.៧៩៥,៤៧ ពាន់លានរៀល មានប្រមាណ ៤៨,៧ ភាគរយ នៃចំណាយចរន្ត សរុប ឆ្នាំ ២០១៤ បានកើនឡើង២២,៩ ភាគរយ ធៀបនឹងឆ្នាំ ២០១៤ ឬស្មើ ៥,៦ ភាគរយនៃផសស ។ ការកើនឡើងនេះ គឺដោយសាររាជរដ្ឋាភិបាលផ្តោតការយកចិត្តទុកដាក់ ពិសេសលើការដំឡើង បៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំង ប្រដាប់អាវុធគ្រប់ប្រភេទ។ ចំណាយ មូលធនអនុវត្តបាន ៥.៥៩០,៧២ ពាន់លានរៀល គឺទាបជាង ០,៤៣ ភាគរយ ធៀបនឹងឆ្នាំ ២០១៣ ក្នុងនោះ ហិរញ្ញប្បទានក្រៅប្រទេសទទួលបាន ប្រមាណ ៧៧,១១ ភាគរយ ឬថយចុះ ១,០១ ភាគរយ ធៀបឆ្នាំ ២០១៣ ។

នៅឆ្នាំ ២០១៤ អតិរេកចរន្តមានចំនួន ២.៣៣២,៣០ ពាន់លានរៀល គឺបានកើនឡើង ៤០,០៤ ភាគរយ ធៀប ឆ្នាំ ២០១៣ ។ កំណើននេះជួយឲ្យរាជរដ្ឋាភិបាលបង្កើនសមត្ថភាពវិនិយោគពីប្រភពថវិកាផ្ទាល់លើ វិស័យអទិភាព ពិសេសលើកស្ទួយផលិតភាព និងកំណើនសេដ្ឋកិច្ច បង្កើនការសន្សំដើម្បីទប់ស្កាត់ហានិភ័យនាពេលអនាគត និង គ្រប់គ្រងសេវាបំណុលប្រកបដោយចីរភាព។ តុល្យភាពសរុបមានឱនភាពចំនួន ៣.០៧៤,៤២ ពាន់លានរៀល ។ រាជរដ្ឋាភិបាលបានធ្វើ ប្រតិបត្តិការហិរញ្ញប្បទានក្រៅប្រទេសចំនួន ៣.៩៧២,០៧ ពាន់លានរៀល ក្នុងនោះមានហិរញ្ញប្បទានសម្រាប់គម្រោង អភិវឌ្ឍន៍ចំនួន ៤.២៦៧,០៨ ពាន់លានរៀល និង សងបំណុលក្រៅប្រទេសមានចំនួន ៣១១,៧៨ ពាន់លានរៀល ។

**៥. វិស័យវិនិយោគ (Private investment)÷** នៅឆ្នាំ ២០១៤ ចំនួនគម្រោងវិនិយោគ មានចំនួន ១៤៨ គឺបានធ្លាក់ចុះ ៤,៥ ភាគរយ ធៀបឆ្នាំ ២០១៣ ដោយសារ គម្រោងវិនិយោគក្នុងវិស័យកសិកម្ម និងឧស្សាហកម្មមានការធ្លាក់ចុះចំនួន ៤ និង ១៤ រៀងគ្នា ។ ទន្ទឹមនឹងនេះ ចំនួនទុនវិនិយោគមានប្រមាណ ១.៥៨៥.១ លានដុល្លារ គឺបានធ្លាក់ចុះ ៦៤,៤ ភាគរយ ដោយសារ ទុនវិនិយោគក្នុងវិស័យកសិកម្ម និងឧស្សាហកម្មមានការថយចុះ ៨៧,១ ភាគរយ និង ៧៥,៦ ភាគរយ ធៀបនឹងឆ្នាំ ២០១៣ ។ រីឯការបង្កើតការងារក៏ដូចគ្នាផងដែរ គឺទទួលបាន ១៧២.៣៨៤ នាក់ បានថយចុះ ២៣,៨ ភាគរយ ធៀបឆ្នាំមុន ដោយសារការបង្កើតការងារក្នុង វិស័យកសិកម្មបានថយចុះ ៨០,៣ ភាគរយ និង ឧស្សាហកម្មបានថយចុះ ២២,២ ភាគរយ ។ ផ្ទុយទៅវិញ ការវិនិយោគឯកជនលើវិស័យសេវាកម្មមានសន្ទុះ កើនឡើងគួរឲ្យកត់សម្គាល់ក្នុងនោះចំនួន គម្រោងបានកើនឡើង ៩ ទុនវិនិយោគ បានកើនឡើង ៣៧៧,១ ភាគរយ និង ការបង្កើតការងារបានចំនួន ៨.២៣១ នាក់ ធៀបនឹងឆ្នាំ ២០១៣ ។

**៦. វិស័យទេសចរណ៍ (Tourism)÷** នៅឆ្នាំ ២០១៤ ចំនួនភ្ញៀវទេសចរណ៍មកដល់កម្ពុជាមានចំនួន ៤,៥០៣ លាននាក់ គឺ បានកើនឡើង ៧,០ ភាគរយ ធៀបនឹងឆ្នាំមុន ក្នុងនោះចំនួនភ្ញៀវទេសចរណ៍មកពីប្រទេសវៀតណាម ចិន និងឡាវ មាន ចំនួនច្រើនជាងគេ ។ ការកើនឡើងនេះគឺដោយសារចំនួនភ្ញៀវទេសចរមកពីប្រទេសចំនួន ដូចជា ចិន ឡាវ ថៃ និង ម៉ាឡេស៊ី បានកើនឡើង ២១,០ ភាគរយ ១១,០ ភាគរយ ២៦,០ ភាគរយ និង ១០,៥ ភាគរយ រៀងគ្នា ធៀបឆ្នាំ ២០១៣ ។ ចំនួន ភ្ញៀវទេសចរដែលធ្វើដំណើរតាមច្រកអាកាសភ្នំពេញ និង សៀមរាបបានកើនឡើង ១២,៧ ភាគរយ តាមផ្លូវទឹក បានកើន ឡើង ២៩,២ ភាគរយ ប៉ុន្តែ តាមផ្លូវគោកបានថយចុះ ០,៦ ភាគរយ ធៀបនឹងឆ្នាំ ២០១៣ ។ ជាងនេះទៅទៀត យើងបានសង្កេតថា ចំនួនភ្ញៀវទេសចរនៅត្រីមាសទីពីរ មានការថយចុះ ២៦,៤ ភាគរយ ធៀប នឹងត្រីមាសទីមួយ ប៉ុន្តែបានកើនឡើងវិញ ៦៧,៦ ភាគរយ នៅត្រីមាសទីបួន ក្នុងឆ្នាំ ២០១៤ ។ ការងើបឡើងនេះគឺ ដោយសារចំនួនភ្ញៀង

ទេសចរណ៍មានលក្ខណៈវដ្តរដូវការជាពិសេសមានចំនួនច្រើន នៅត្រីមាសទី ១ និង ត្រីមាស ទីបួន ប្រមាណជា ៥៨,៨ ភាគរយ នៃចំនួនភ្ញៀវទេសចរណ៍សរុប ។

**៧. វិស័យសំណង់ (Construction) ÷** វិស័យសំនង់នៅតែជាវិស័យមួយយ៉ាងសំខាន់ក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ចនារយៈពេលកន្លងមក ។ នៅឆ្នាំ ២០១៤ ចំនួនគម្រោងស្នើសុំសាងសង់សរុបទូទាំងប្រទេសដែលអនុម័តរួចមានចំនួន ២,៣០១ គម្រោង គឺបានកើនឡើង ១៩,៤៤ ភាគរយ ធៀបឆ្នាំ ២០១៣ ។ កំណើននេះ គឺដោយសារការកើនឡើងនៃគម្រោងសាងសង់ ភាគច្រើនទៅលើ ខុងដូរ លំនៅដ្ឋាន អគារពាណិជ្ជកម្ម ផ្សារលក់ទំនិញ សណ្ឋាគារ និង រោងចក្រ ។ ប៉ុន្តែចំនួនផ្ទៃ ក្រឡា និង ទឹកប្រាក់បានថយចុះ ១៤,៩៦ ភាគរយនិង ៩,៦០ ភាគរយ រៀងគ្នា ធៀបឆ្នាំ ២០១៣ ។ ទន្ទឹមនឹងនេះ ឥណទានផ្តល់ ដោយ ធនាគារពាណិជ្ជទៅវិស័យ សំណង់មានចំនួន ២,៨៥៥ ពាន់លានរៀល គឺបានកើនឡើង ២៣,៨ ភាគរយធៀបនឹងឆ្នាំ ២០១៣ ។ ការកើនឡើងនេះ អាចជាហានិភ័យដល់វិស័យនេះ នៅពេលដែលថ្លៃតម្លៃអចលនទ្រព្យមាន ការធ្លាក់ចុះ ដោយសារការផ្គត់ផ្គង់ហួសតម្រូវការ ។ ម្យ៉ាងទៀត ប្រសិនបើតម្រូវការពីអ្នកទិញលើ វិស័យនេះមានការធ្លាក់ចុះ នោះវាអាចប៉ះពាល់ដល់អ្នកជំពាក់បំណុលដែលអាចនឹងគ្មានលទ្ធភាពសងទៅធនាគារវិញ ហើយប្រទេសអាចជួបវិបត្តិ ប្រសិនបើគ្មានវិធានការកាត់បន្ថយឥណទានក្នុងវិស័យនេះ។

**៨. ថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (Crude oil price average: Brent, Dubai and WTI) ÷** នៅខែ ធ្នូ ឆ្នាំ ២០១៤ តម្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិ (WTI) សម្រាប់កិច្ចសន្យាលក់ មួយខែខាងមុខបានថយចុះ ១៥,៤ ភាគរយ ធៀបទៅនឹងខែមុន គឺពី ៨៣,០ ដុល្លារ/ធុង មក ៦១,៧ ដុល្លារ/ធុង ។ ចំពោះ (Brent) បានថយចុះ ១៤,៥ ភាគរយ ធៀបទៅនឹងខែមុន គឺពី ៧៧,១ ដុល្លារ/ធុង មក ៦៥,៩ ដុល្លារ/ធុង ។

តំលៃប្រេងឆៅបានបន្តធ្លាក់ចុះ គឺដោយសារស្តុកប្រេងអាមេរិកនៅតែបន្តកើនឡើង ទន្ទឹមនឹងបរិមាណផ្គត់ផ្គង់ប្រេងលើទីអន្តរជាតិរបស់ប្រទេសជាសមាជិកអង្គការ OPEC នៅតែមានកំណើនខ្ពស់ ជាពិសេសប្រទេសអារ៉ាប៊ីសាអូឌីតបានបង្កើនការផលិតសម្រាប់ការនាំចេញ ។ ថ្មីៗនេះប្រទេសអាល់ហ្សេរីបានស្នើប្រទេសអារ៉ាប់ប៊ីសាអូឌីតឱ្យបន្ថយការផលិតប្រេងដើម្បីទប់ថ្លៃប្រេងកំពុងធ្លាក់ចុះខ្លាំងនៅលើទីផ្សារ ។ តបនឹងសំណើរនេះ ប្រទេសអារ៉ាប់ប៊ីសាអូឌីតបានលើកឡើងថាខ្លួននឹងមិនកាត់បន្ថយការផលិតប្រេងទេ បើទោះបីជាប្រេងឥន្ធនៈបាបនធ្លាក់ចុះទាបក៏ដោយ ពីព្រោះការកាត់បន្ថយ ការផលិតនាំឱ្យប្រទេស ផលិតប្រេងដែលមិនមែនជាសមាជិករបស់ OPEC អាចទាញយកផលចំណេញបាន ។ តាមការសង្កេតថ្លៃប្រេងឆៅនៅលើទីផ្សារអន្តរជាតិគួរស្ថិតនៅក្នុងរង្វង់ពី ៦០ ទៅ ៨០ ដុល្លារ/ធុង ទើបប្រទេសជាសមាជិក របស់ OPEC ដែលចំណូលជាង ៦០ ភាគរយ របស់ខ្លួនមកពឹងការលក់ប្រេង អាចធានាបាន ។

**៩. ថ្លៃអង្ករនៅលើទីផ្សារអន្តរជាតិ (Rice price: 5%, 25% and 100% broken) ÷** នៅខែ ធ្នូ ឆ្នាំ ២០១៤ តម្លៃអង្ករនៅទីផ្សារកម្ពុជាប្រភេទនៅទីក្រុងបាងកកអង្ករនាំចេញ (ខ្ទេច ២៥ ភាគរយ) មានតម្លៃ ៣៩៨ ដុល្លារ/តោន គឺ បានថយចុះ ០,៥ ភាគរយ ធៀបទៅនឹងខែមុនដែលមានតម្លៃ ៤០០ ដុល្លារ/តោន ។ ការធ្លាក់ចុះបណ្តាលមកពីដល់រដូវប្រមូលផលថ្មី និងស្តុកអង្ករនៅតែរក្សា បរិមាណខ្ពស់ (១៧,៨ លានតោន) នៅចុងឆ្នាំ ២០១៤ នេះ ។ តាមធម្មតារដ្ឋាភិបាលតែងតែបញ្ចុះថ្លៃអង្ករនៅដើមឆ្នាំ ដើម្បីទាក់ទាញបណ្តា ប្រទេសនាំចូលអង្ករ ដូចជាប្រទេសចិនជាដើមក្នុងការជម្រុញការនាំចេញ ។

ចំណែកឯនៅប្រទេសវៀតណាមវិញ នៅខែ ធ្នូ ឆ្នាំ ២០១៤ អង្ករនាំចេញ (ខ្ទេច ៥ ភាគរយ) មានតម្លៃ ៣៨២,៤ ដុល្លារ/តោន បានថយចុះប្រមាណ ៩,៤ ភាគរយ ធៀបទៅនឹងខែមុន ។ ការធ្លាក់ចុះបណ្តាលមកពីការកើនឡើង ការផ្គត់ផ្គង់នៅក្នុងតំបន់ ដូចជាប្រទេសថៃ ប្រទេសឥណ្ឌាជាដើម ។

ជាការសង្កេតតម្លៃអង្ករក្នុងឆ្នាំ ២០១៤ នេះ បានថយចុះខ្លាំងដោយសារប្រទេសថៃ ដែលជាប្រទេសនាំចេញអង្ករធំជាងគេ បានបញ្ចេញអង្ករចេញពីស្តុករបស់ខ្លួនចូលទៅក្នុងទីផ្សារស្របពេលដែលតម្រូវការប្រើប្រាស់នៅមានកម្រិតទាបនៅឡើយ។

**១០. ថ្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិ (Rubber price: SGP/MYS, TSR20)** ÷ នៅខែ ធ្នូ ឆ្នាំ ២០១៤ កៅស៊ូធៅស្តង់ដារ TSR 20 មានថ្លៃ ១,៤៨ ដុល្លារ/គីឡូ គឺបាន ថយចុះ ៤,៣ ភាគរយ បើប្រៀបធៀបទៅនឹងខែមុន ដែលថ្លៃ ១,៥៤ ដុល្លារ/គីឡូ។ ការធ្លាក់ថ្លៃកៅស៊ូនេះបណ្តាលមកពី តំរូវការពីទីផ្សារអន្តរជាតិមានការថយចុះ ជាពិសេសប្រទេសចិន និងប្រទេសសហគមន៍អ៊ឺរ៉ុប ដែលកំពុងមាន ការថមថយ លើកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ជាការសង្កេតតម្លៃប្រេងគឺជាកត្តាកំណត់ថ្លៃ ដើមមួយចំនែកនៃកៅស៊ូ ជាពិសេសប្រេងកាត ដែលត្រូវបានគេប្រើប្រាស់ជាទូទៅសម្រាប់ផលិតកៅស៊ូ។ ដូចនេះការធ្លាក់ចុះតម្លៃប្រេងក៏ជាកត្តាជម្រុញឱ្យតម្លៃកៅ ស៊ូធ្លាក់ចុះផងដែរ ។ មួយវិញទៀត ប្រទេសថៃដែលជាប្រទេសធំជាងគេក្នុងការនាំចេញកៅស៊ូបានបង្ហាញតួលេខ ផលិតកម្ម ប្រមាណ ៤,០២ លានតោន ដែលកើនឡើងប្រមាណ ៤,៣៦ ភាគរយ ។ ក៏ប៉ុន្តែតម្លៃនាំចេញរបស់កៅស៊ូថៃបានធ្លាក់ចុះ ប្រមាណ ២១,៣ ភាគរយ ផងដែរដោយសារតម្រូវការក្នុងសម្រាប់ ឧស្សាហ៍កម្មរថយន្តបានថយចុះប្រមាណ ១៣,៥៥ ភាគរយ។ គួររំលឹកដែរថា នៅដើមឆ្នាំ ២០១៤ ស្តុកកៅស៊ូរបស់ ថៃកើនឡើងដោយសារបញ្ហាទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលបង្អាកដល់ផលិតកម្ម កៅស៊ូនៅក្នុងប្រទេស ។

***********

## ១១. ឧបសម្ព័ន្ធ (Index)

### សូចនាករនាំមុខ (Leading Indicators)

**Tourist Arrivals ('000 persons)**




Source: Ministry of Tourism

**Total Textile Export (Mn-US$)**




Source: Customs and Excise Dept.

**Import of Gasoline, Steel, Cement ('000T)**




Source: Customs and Excise Dept.

**Construction Approval in P-Penh (m2)**




Source: Min. LMUC

**Rice Prices in Bangkok and Vietnam 2003 = 100**




Source: MEF & Int.

**Crude oil and Gasoline Price, Jan 2003 = 100**




Source: MEF & Int.

# អតិផរណា និង ទុនបំរុងបរទេស (Inflation and Foreign Reserves)


















# អត្រាប្តូរប្រាក់ (Exchange Rate)

**Exchang Rate Mal-Ringgit/$ and Phi-Peso/$**




Source: IMF

**CPI and Exchange rate R/$**




Source: IMF

**Exchange rate EU Euro/US$ and Pound/US$**




Source: IMF

**Exchange rate R/100Đ and R/B**




Source: IMF

**Exchange rate Aus-$ and HK-$**




Source: IMF

**Exchange rate Sing-$ and Yen-$**




Source: IMF

# វិស័យរូបិយវត្ថុ និងធនាគារ (Money and Banking)

**Liquidity in Bn-R and in % to GDP**




Source: NBC

**NFA and NDA (Bn-R)**




Source: NBC

**Credit to private sector, CPS (Stock) and growth**




Source: NBC

**Credit to Private Sectors by Sector (Bn-R)**




Source: NBC

**Currency outside bank, COB and foreign deposits, FD**




Source: NBC

**MFIs and NGOs Loans Outstanding**




Source: NBC

# ការអនុវត្តថវិកា (Budget)







Source: MEF




Source: MEF




Source: MEF




Source: MEF




Source: MEF

# វិនិយោគឯកជន និង ការបង្កើតការងារ (Investment and Employment)

**CDC Approval, Fixed Assets and Growth (Mn. $)**




Source: CDC

**CDC Approvals- Fixed Assets by Sectors (Mn. $)**




Source: CDC

**Number of Jobs ('000 person)**




Source: CDC

**Public Investment by Source of Finance (Bn.R)**




Source: MEF

**Net Loans Disbursement (Bn.R)**




Source: MEF

**CDC Approvals, Fixed assets by Sources (Mn. $)**




Source: CDC

# ទិស័យពាណិជ្ជកម្ម (Trades)
















